សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

HAPPY KHMER NEW YEAR

ឯកឧត្តម ហ៊ុន ម៉ានី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមជម្រាបជូន
ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ: ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជាទីគោរព!

ក្នុងឱកាសដ៏មហាពិសិទ្ធបូជ្ញ ប្រកបដោយសេចក្ដីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខាងមុខនេះ: តាងនាមជ្លាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូនពរសព្វសាធុការណរដ្ឋ សិរីមង្គល វិបុលសុខ មហាប្រសើរជូន **ឯកឧត្តម** សូមទទួលបាននូវសុខភាពល្អហើបរ៉ូ កម្លាំងកាយហ៊ាមមួន បញ្ញាញាណងងឹ ជន្មាយុយឺនឃ្យេ ដើម្បីរួមចំណែកជាមួយជ្លាក់ថ្នាក់ដឹកនាំប្រទេសជាតិឱ្យកាន់តែដិតមាំ ឆ្ពោះទៅការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពសម្បូរសប្បាយរុងរឿង។

ម្យ៉ាងក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមនោសញ្ចេតនាគោរពស្រឡាញ់យ៉ាងស្មោះស្ម័គ្រចំពោះ: **ឯកឧត្តម** ដែលបានលះបង់កម្លាំងកាយចិត្ত ប្រាជ្ញា ស្មារតី និងភាពបិនប្រសប់ ប្រកបដោយគតិបណ្ឌិត សក្តានុពល ក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមដ៏ផ្ទ ជាតិ សាសនា ព្រះមហាក្សត្រ។ ជាពិសេសក្រោមការដឹកនាំរបស់ **ឯកឧត្តម** បានដំណើរការដោយកើតទម្រង់រ៉ៃយមុខងារសាធារណៈ: ស្ថិតក្នុងស្ថានភាពមានស្ថិរភាពល្អ ជាលទ្ធផលល្អជាលក្ខណៈ ស្របទៅតាមការអនុវត្ត "យុទ្ធសាស្ត្របញ្ចកោណ" បានសក្តានុពលជ្ញាតិបាល ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដឹកនាំ ។

ជាចុងក្រោយទៀត តាងនាមជ្លាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំនិងភរិយា សូមបួងសួងបំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុសក្ដិសិទ្ធិទាំងមានក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាវ៉ាយក្សទីកដ៏ នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្ដោះព្រំនូវសព្វសាធុការណដ៏ផ្ទ ជូន **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខ: ពល: កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**: ទទួលនូវការគោរពប់អានពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៦
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ម៉ៅ សីហា

ទីស្នាក់ការ៖ សង្កាត់ទន្លេបាសាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស្ព័ទ្ធលេខ ០១៣ ២១៥ ២១៥ email: generalsec@mod.gov.kh